# ការអត់ឱន
# ទោស

ព្រះវរបិតាអើយ ខ្ញុំចូលមករកទ្រង់ ដ្បិតខ្ញុំនឿយហត់ ហើយមានបន្ទុកធ្ងន់ទៀត មានមនុស្សបានធ្វើបាបខ្ញុំ ប៉ុន្តែខ្ញុំបានរៀនពីទ្រង់ ដ្បិតទ្រង់ស្លូត ហើយមានចិត្តសុភាព។ (១)

ខ្ញុំនឹងមិនព្រមឱ្យសេចក្ដីជូរល្វីង លេចឡើងនៅក្នុងចិត្តរបស់ខ្ញុំនោះទេ ប៉ុន្តែខ្ញុំនឹងដកអស់ទាំងការខកចិត្ត ក្តៅក្រហាយ កំហឹង និងភាពអវិជ្ជមាន ចេញពីខ្លួនរបស់ខ្ញុំវិញ។ (២)

ដ្បិតខ្ញុំមិនមែនតយុទ្ធនឹងសាច់ឈាមទេ ប៉ុន្តែ ខ្ញុំតយុទ្ធនឹងពួកគ្រប់គ្រង នៅស្ថានដ៏ខ្ពស់ដែរ។ (៣)

ខ្ញុំបានជ្រើសរើសការមិនសងសឹក ដ្បិតការសងសឹក នោះស្រេចនឹងទ្រង់ ហើយទ្រង់នឹងសងដល់គេវិញ។ (៤)

ដូច្នេះ ខ្ញុំបានអត់ទោស ឱ្យអស់អ្នកណាដែលដាក់បណ្តាសាមកលើខ្ញុំ ព្រមទាំងឲ្យពរដល់ពួកគេ។ (៥)

ទ្រង់ជាព្រះដែលប្រុងនឹងអត់ទោស ទ្រង់ក៏សន្តោស ហើយមេត្តាករុណា ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្តីសប្បុរសជាបរិបូរ។ (៦)

នោះហើយជាមូលហេតុ ដែលខ្ញុំរៀនពីទ្រង់ ហើយទ្រង់នឹងឱ្យ ខ្ញុំបានសេចក្តីសំរាកដល់ព្រលឹង។ (១)

(១) ម៉ាថាយ ១១ : ២៩ (៤) រ៉ូម ១២ : ១៩
(២) អេភេសូរ ៤ : ៣១ (៥) រ៉ូម ១២ : ១៤
(៣) អេភេសូរ ៦ : ១២ (៦) នេហេមា ៩ : ១៧

**ម៉ាថាយ ១១ : ២៩** ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្តីសំរាកដល់ព្រលឹង។(១)

**អេភេសូរ ៤ : ៣១** ចូរខំដកគ្រប់ទាំងសេចក្តីជូរល្វីង ក្តៅក្រហាយ កំហឹង ឡូឡា ជេរប្រមាថ និងគ្រប់ទាំងសេចក្តីអាក្រក់ ចេញពីពួកអ្នករាល់គ្នាទៅ។ (២)

**អេភេសូរ ៦ : ១២** ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺ និងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកីយ៍នេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណនៅស្ថានដ៏ខ្ពស់ដែរ។ (៣)

**រ៉ូម ១២: ១៩** ឱពួកស្ងួនភ្ងាអើយ កុំឲ្យសងសឹកឡើយ ចូរថយចេញពីសេចក្តីកំហឹងទៅ ដ្បិតមានសេចក្តីចែងទុកមកថា «ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា ការសងសឹក នោះស្រេចនឹងអញ អញនឹងសងដល់គេ» ។ (៤)

**រ៉ូម ១២: ១៤** ចូរសូមពរឲ្យដល់អ្នកណាដែលបៀតបៀនអ្នក ចូរសូមពរចុះ កុំឲ្យប្រទេចផ្តាសាឡើយ។ (៥)

**នេហេមា ៩: ១៧** គេមិនព្រមធ្វើតាមបង្គាប់ឡើយ ក៏មិននឹកចាំពីអស់ទាំងការអស្ចារ្យដែលទ្រង់បានធ្វើ នៅកណ្តាលពួកគេផង គឺគេបានតាំងករឹងវិញ ក្នុងគ្រាបះបោរនោះ គេបានតម្រូវម្នាក់ឲ្យធ្វើជាមេ ដើម្បីនឹងនាំវិលទៅឯសណ្ឋានជាបាវបំរើវិញ តែទ្រង់ជាព្រះដែលប្រុងនឹងអត់ទោស ទ្រង់ក៏សន្តោស ហើយមេត្តាករុណា ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្តីសប្បុរសជាបរិបូរ បានជាទ្រង់មិនបោះបង់ចោលគេឡើយ។ (៦)

បកប្រែដោយៈ ONE- -2 ONE CAMBODIA
អាស័យដ្ឋានៈ # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦
សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
www.One-2-One world.org
www.derekprince.co.nz PC07